# ឯកសារតម្រូវសម្រាប់ការបើកគណនីរក្សាសុវត្ថិភាព

## ឯកត្តជន

- ចំពោះជនជាតិខ្មែរ អតិថិជនត្រូវមានឯកសារមួយក្នុងចំណោមឯកសារខាងក្រោម ៖
  - o អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ ឬ
  - o លិខិតឆ្លងដែន ដែលនៅមានសុពលភាពយ៉ាងតិច បីខែ ឬ
  - o សៀវភៅគ្រួសារ (ករណីអតិថិជនជាមេគ្រួសារ) ឬ
  - o សៀវភៅគ្រួសារ (ករណីអតិថិជនជាសមាជិកគ្រួសារ) ឬសៀវភៅស្នាក់នៅ ដោយត្រូវភ្ជាប់ឯកសារផ្សេងៗដែលមានរូបថត ដូចជា អត្តសញ្ញាណប័ណ្ណមន្ត្រីរាជការ ឬអត្តសញ្ញាណប័ណ្ណការងារ ឬប័ណ្ណបើកបរ ឬប័ណ្ណសម្គាល់ខ្លួនសិស្ស-និស្សិត ជាដើម
  - o អត្តសញ្ញាណវិនិយោគិន
- ចំពោះជនជាតិបរទេស អតិថិជនត្រូវមាន ៖
  - o លិខិតឆ្លងដែន ដែលនៅមានសុពលភាពយ៉ាងតិច បីខែ
  - o អាសយដ្ឋានពិតប្រាដកដែលអាចទាក់ទងបាននៅកម្ពុជា ដោយមានបញ្ជាក់ទីលំនៅចេញដោយអាជ្ញាធរមានសមត្ថកិច្ច ឬលិខិតបញ្ជាក់ពីថ្នាក់មានសមត្ថកិច្ចរបស់ស្ថាប័នកំពុងបម្រើការងារ ឬកិច្ចសន្យាការងារ ឬកិច្ចសន្យាអាជីវកម្មជាមួយដៃគូជំនួញនៅកម្ពុជា ឬលិខិតបញ្ជាបេសកកម្មពីក្រៅប្រទេសរបស់ស្ថាប័នដែលអាចទុកចិត្តបាន
  - o លេខទូរស័ព្ទ ទូរសារ ឬអ៊ីម៉ែល ដែលអាចទាក់ទងបាន
  - o អត្តសញ្ញាណវិនិយោគិន

## ព័ត៌មាន និងលក្ខខណ្ឌតម្រូវផ្សេងៗសម្រាប់បើកគណនីពីក្រៅប្រទេស

ធនាគារអេស៊ីលីដា អនុញ្ញាតឱ្យលោកអ្នក ដែលរស់នៅ ឬមានទីតាំងប្រតិបត្តិការអាជីវកម្មនៅបរទេស អាចបើកគណនីធ្វើប្រតិបត្តិការដក-ដាក់ប្រាក់ ឬផ្ទេរប្រាក់ និងបិទគណនីពីក្រៅប្រទេស ជាមួយធនាគារអេស៊ីលីដា ដោយអនុលោមទៅតាមលក្ខខណ្ឌទាំងឡាយរបស់ធនាគារអេស៊ីលីដា និងច្បាប់របស់ព្រះរាជាណាចក្រកម្ពុជា ។

- អតិថិជនត្រូវបំពេញពាក្យស្នើសុំចុះឈ្មោះបើកគណនី (ទម្រង់បើកគណនីឯកត្តជន និងគំរូហត្ថលេខា ឬស្នាមមេដៃបើកគណនីឯកត្តជន) រួមទាំងលក្ខខណ្ឌពិសេសក្នុងការប្រតិបត្តិគណនី ជាមួយធនាគារ អេស៊ីលីដា ភីអិលស៊ី ពីក្រៅប្រទេស និងភ្ជាប់មកជាមួយនូវច្បាប់ថតចម្លងលិខិតឆ្លងដែន (នៅមានសុពលភាពយ៉ាងតិច ៣ខែ)។
- ពាក្យស្នើសុំចុះឈ្មោះបើកគណនី និងឯកសារតម្រូវខាងលើ ត្រូវបញ្ជាក់ដោយសារការីនៅក្រៅប្រទេស ឬអាជ្ញាធរមានសមត្ថកិច្ចពាក់ព័ន្ធ (ករណីប្រទេសគ្មានសារការី) និងត្រូវបញ្ជាក់បន្ថែមដោយ ៖
  - o ស្ថានទូត ឬស្ថានតំណាងរបស់អតិថិជនសាមី ប្រចាំនៅកម្ពុជា ឬ
  - o សារការីនៅក្នុងប្រទេសកម្ពុជា (ករណីគ្មានស្ថានទូត) ឬ
  - o ធនាគារអន្តរការី តាម SWIFT Message MT999 មកធនាគារ អេស៊ីលីដា ភីអិលស៊ី
- អត្តសញ្ញាណវិនិយោគិន

## នីតិបុគ្គល

- អនុស្សរណៈ និងលក្ខន្តិកៈ វិញ្ញាបនបត្រចុះបញ្ជីពាណិជ្ជកម្ម ភាពជាដៃគូ ដែលសមស្របតាមសភាពជាក់ស្តែង
- ឯកសារសម្គាល់អត្តសញ្ញាណរបស់ម្ចាស់គណនី
- លិខិតអនុញ្ញាតអាជីវកម្ម ឬឱ្យដំណើរការអង្គភាព

- ប័ណ្ណប៉ាតង់ វិញ្ញាបនបត្រចុះបញ្ជីអាករលើតំលៃបន្ថែម លិខិតបញ្ជាក់ការបង់ប្រាក់ពន្ធ ឬលិខិតប្រកាសពន្ធផ្សេងៗ ដែលមានលិខិតអត្តសញ្ញាណកម្មសារពើពន្ធ
- ឯកសារសម្គាល់អត្តសញ្ញាណរបស់នាយក ភាគហ៊ុនិក ឬដៃគូ
- សេចក្តីសម្រេចចិត្តរបស់ក្រុមប្រឹក្សាភិបាល ឬនាយកគ្រប់គ្រង លើការបើកគណនី
- លិខិតផ្ទេរសិទ្ធិដល់បុគ្គលណាម្នាក់ជាតំណាងឱ្យក្រុមហ៊ុន ឬអាជីវកម្ម
- ឯកសារពាក់ព័ន្ធផ្សេងៗទៀត ។
- អត្តសញ្ញាណវិនិយោគិន

**ព័ត៌មាន និងលក្ខខណ្ឌតម្រូវផ្សេងៗសម្រាប់បើកគណនីពីក្រៅប្រទេស**

ធនាគារអេស៊ីលីដា អនុញ្ញាតឱ្យលោកអ្នក ដែលរស់នៅ ឬមានទីតាំងប្រតិបត្តិការអាជីវកម្មនៅបរទេស អាចបើកគណនីធ្វើប្រតិបត្តិការដក-ដាក់ប្រាក់ ឬផ្ទេរប្រាក់ និងបិទគណនីពីក្រៅប្រទេស ជាមួយធនាគារអេស៊ីលីដា ដោយអនុលោមទៅតាមលក្ខខណ្ឌទាំងឡាយរបស់ធនាគារអេស៊ីលីដា និងច្បាប់របស់ព្រះរាជាណាចក្រកម្ពុជា ។

- អតិថិជនត្រូវបំពេញពាក្យសុំចុះឈ្មោះបើកគណនី (ទម្រង់បើកគណនីក្រុមហ៊ុន និងគំរូហត្ថលេខាបើកគណនីក្រុមហ៊ុន) និង/ឬ ពាក្យស្នើសុំបើកគណនីពីអ្នកមានសិទ្ធិ (ករណីមានការផ្ទេរសិទ្ធិ ឬករណីអ្នកតំណាងក្រុមហ៊ុនស្នើសុំបើកគណនី) រួមទាំងលក្ខខណ្ឌពិសេសក្នុងការប្រតិបត្តិគណនី ជាមួយធនាគារ អេស៊ីលីដា ភីអិលស៊ី ពីក្រៅប្រទេស និងបោះត្រាក្រុមហ៊ុន ដោយភ្ជាប់មកនូវឯកសារ ដូចខាងក្រោម ៖
    - អនុស្សរណៈ និងលក្ខន្តិកៈក្រុមហ៊ុន ឬស្ថាប័ន
    - អាជ្ញាប័ណ្ណ វិញ្ញាបនបត្រចុះបញ្ជីពាណិជ្ជកម្ម ឬលិខិតអនុញ្ញាតឱ្យដំណើរការក្រុមហ៊ុន ឬស្ថាប័ន
    - ច្បាប់ថតចម្លងលិខិតឆ្លងដែន (នៅមានសុពលភាពយ៉ាងតិច ៣ខែ) របស់អ្នកស្នើសុំ និងសមាជិកក្រុមប្រឹក្សាភិបាល ឬអ្នកមានសិទ្ធិ
    - លិខិតប្រគល់សិទ្ធិ ឬសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាភិបាល
    - គោលការណ៍ប្រឆាំងការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម ករណីជាគ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុ ឬស្ថាប័នហិរញ្ញវត្ថុ
    - របាយការណ៍ហិរញ្ញវត្ថុ ឬរបាយការណ៍ប្រចាំឆ្នាំ ប្រសិនបើមាន
- ពាក្យស្នើសុំចុះឈ្មោះបើកគណនី (ទម្រង់បើកគណនីក្រុមហ៊ុន និងគំរូហត្ថលេខាបើកគណនីក្រុមហ៊ុន) និង/ឬ ពាក្យស្នើសុំបើកគណនីពីអ្នកមានសិទ្ធិ (ករណីមានការផ្ទេរសិទ្ធិ ឬករណីអ្នកតំណាងក្រុមហ៊ុនស្នើសុំបើកគណនី) រួមទាំងលក្ខខណ្ឌពិសេសក្នុងការប្រតិបត្តិគណនី ជាមួយធនាគារ អេស៊ីលីដា ភីអិលស៊ី ពីក្រៅប្រទេស និងឯកសារតម្រូវខាងលើ ត្រូវបញ្ជាក់ដោយសារការីនៅក្រៅប្រទេស ឬអាជ្ញាធរមានសមត្ថកិច្ចពាក់ព័ន្ធ (ករណីប្រទេសគ្មានសារការី) ដែលអតិថិជនរស់នៅ និងត្រូវបញ្ជាក់បន្ថែមដោយ ៖
    - ស្ថានទូត ឬស្ថានតំណាងរបស់អតិថិជនសាមី ប្រចាំនៅកម្ពុជា ឬ
    - សារការីនៅក្នុងប្រទេសកម្ពុជា (ករណីគ្មានស្ថានទូត) ឬ
    - តាម SWIFT Message MT999:
        - ករណីអតិថិជនជាប្រភេទក្រុមហ៊ុនអាជីវកម្មទូទៅ ត្រូវធ្វើតាម SWIFT Message MT999 របស់ធនាគារអន្តរការី
        - ករណីអតិថិជនជាប្រភេទគ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុ អាចធ្វើតាម SWIFT Message MT999 ផ្ទាល់ខ្លួនរបស់អតិថិជន/របស់ធនាគារអន្តរការី
- អត្តសញ្ញាណវិនិយោគិន